**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការខេត្តកំពង់ធំ

សាលក្រម

លេខ ១៥ ក ចុះថ្ងៃទី ០៦

ខែ មេសា ឆ្នាំ ២០០៥

សំណុំរឿង

លេខ ១០៧ ចុះថ្ងៃទី ២០

ខែ សីហា ឆ្នាំ ២០០៤

*សាលក្រមនេះចូលស្ថាពរចាប់តាំងពីថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៥ តទៅ*
*ដោយគូក្តីមិនចូលតវ៉ាតាមកំណត់ច្បាប់ ។*
*កំពង់ធំ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៥*
***ប្រធានតុលាការខេត្ត***
[redacted]

**តាងនាមប្រជារាស្ត្រខ្មែរ**

តុលាការខេត្តកំពង់ធំ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅទីតុលាការខេត្តកំពង់ធំ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជំរះ**

លោក [redacted]

**តំណាងអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ១០៧ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៤ ដែលមានកម្មវត្ថុបណ្តឹង : **ប្តឹងសុំឱ្យរុះរើតូបចេញពីមុខបួងដីលំនៅដ្ឋាន ។**

-រវាងដើមចោទ **ល មថ** ភេទប្រុស អាយុ ៥២ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃនៅភូមិកំពង់ធំ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ របររកស៊ី អនុប្រធានមន្ទីរឧស្សាហកម្មរ៉ែ និង ថាមពលខេត្ត ប្រពន្ធឈ្មោះ **ច សម** មានកូន ០៤នាក់ ឪពុកឈ្មោះ **យ ល** (ស) ម្តាយឈ្មោះ **គ ឡ៉ុ** ។ ទោសពីមុន *គ្មាន* ។

-និង ចុងចម្លើយឈ្មោះ **ល យគ** ភេទស្រី អាយុ ៦៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃនៅភូមិកំពង់ធំ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ របររកស៊ីនៅផ្ទះ ប្តីឈ្មោះ **គ ផ** (ស) មានកូន ០៤នាក់ ឪពុកឈ្មោះ **ល ទ** (ស) ម្តាយឈ្មោះ **យ ព** (ស) ទោសពីមុន *គ្មាន* ។

## **ដំណើររឿងហេតុមានដូចតទៅ**

តាមពាក្យបណ្តឹងចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៤ របស់ដើមចោទឈ្មោះ **ល មថ** បានប្តឹងសុំអោយរុះរើតូបចេញពីមុខបួងដីលំនៅដ្ឋានពីឈ្មោះ **ល យគ** ដោយសំអាងហេតុថា ខ្លួនបានកាន់កាប់គ្រប់គ្រងដីលំនៅដ្ឋាននេះតាំងពីឆ្នាំ ១៩៨៦ មកមានទំហំ ០១អារ៦៩សង់ទីអារ ដីនេះប្រពន្ធខ្លួនបានទិញពីបងស្រីបង្កើត ដែលគាត់កាន់កាប់តាំងពីឆ្នាំ ១៩៧៩ មក ឯឈ្មោះ **ល យគ** គាត់មកធ្វើតូបលក់ទឹកកកនៅពីមុខបួងខ្លួន ហើយមានបំពេញធ្វើជាផ្ទះថ្មធំពីរជ ន់ជាច្រើនលើក ទើបខ្លួនប្តឹងមកតុលាការ

ខេត្តតែម្តង ។

-បានឃើញរបាយការណ៍ជូនរឿងទៅជំនុំជំរះលេខ ១៦៦ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១៦៧ ចុះថ្ងៃទិ ២១ ខែ មីនា ឆ្នាំ ២០០៥ ។

## នាពេលសវនាការ

-ដើមចោទឈ្មោះ ល ម៩ បានឆ្លើយបញ្ជាក់ថា ដីលំនៅដ្ឋានដែលកំពុងរស់នៅសព្វថ្ងៃ ខ្លួនបានទិញពីឈ្មោះ គ សហ ប្រពន្ធ អ មហ កាលពីឆ្នាំ ១៩៨៦ ដែលគាត់កាន់កាប់តាំងពីឆ្នាំ ១៩៧៩ មកដល់ឆ្នាំ ១៩៩៥ ខ្លួនបានធ្វើប័ណ្ណសំគាល់កម្មសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ហាស់៣:៣៦៨ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៥ ឯឈ្មោះ ល យគ គាត់មកដាក់ដេប៉ូលក់ទឹកកកនៅពីមុខប្លង់ដីលើចំណីថ្នល់ជាតិលេខ ៦ ជ្រុងខាងក្បូងផ្ទះរបស់ខ្លួន ។ ការលក់ទឹកកកនេះកាលពីមុនតូបតូចទេ ក្រោយមកធ្វើធំមានចាក់គ្រឹះ តែខ្លួនប្តឹងទៅរដ្ឋអំណាចខេត្តក៏បានដោះស្រាយឱ្យគាត់ដែកដែលបណ្តុះចាក់គ្រឹះនោះចេញម្តងហើយ ។ តែការរស់នៅកន្លងមកចុងចម្លើយនៅតែមានចរិកមានបង្កទំនាស់ជាច្រើនលើកអំពីតូបនេះ ហើយថែមទាំងធ្វើតូបពង្រីកឱ្យធំទំហំ ៤.៤៥ម x ២.៩ម ក៏ត្រូវចូលក្នុងប្លង់ដីខ្លួនអស់ទំហំ ៤.៤៥ម x ១.៣ម តែបើវាស់ពីទ្រូងថ្នល់ជាតិលេខ៦ ទៅប្លង់ដីខ្លួនខាងលិចថ្នល់ប្រវែង ១៥ម តាមសេចក្តីប្រកាសលេខ ០៦ប្រក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលនេះឃើញថា តូបនេះស្ថិតនៅលើដីចំណីថ្នល់ទាំងស្រុង ។ លុះដល់ឆ្នាំ ២០០៤ នេះចុងចម្លើយមានបំណងសាងសង់តូបនោះទៀត ទើបខ្លួនប្តឹងសុំឱ្យរុះរើតូបនោះចេញពីមុខប្លង់ដីរបស់ខ្លួនមកតុលាការខេត្តតែម្តង ។ ប៉ុន្តែបើចុងចម្លើយព្រមរុះរើតូបនោះចេញពីប្លង់ដីខ្លួន ខ្លួនសុខចិត្តប្រគល់ប្រាក់ឱ្យចុងចម្លើយចំនួន ១.០០០ដុល្លាអាមេរិកដើម្បីបញ្ចប់រឿងនេះ ។

-ចុងចម្លើយឈ្មោះ ល យគ បានឆ្លើយបញ្ជាក់ថា ចំពោះការប្តឹងទាមទាររបស់ដើមចោទសុំគ្រប់គ្រងដីដែលមានតូបរបស់ខ្លួនលក់ដូរបច្ចុប្បន្ននេះខ្លួនឯកភាពប្រគល់ដីនោះឱ្យបាន តែសុំឱ្យដើមចោទប្រគល់ប្រាក់ចំនួន ១.០០០ ដុល្លាមកអោយខ្លួនសំរាប់ចំណាយក្នុងការរុះរើតូប ។

-សាក្សីដើមចោទឈ្មោះ គ សហ បានឆ្លើយបញ្ជាក់ថា ដីទំនាស់នេះ គឺជាដីខ្លួនកាន់កាប់តាំងពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨៦ ខ្លួនបានលក់អោយទៅឈ្មោះ ច សហ ប្រពន្ធរបស់ ល ម៩ ជាដើមចោទ ពួកគេក៏កាន់កាប់រហូតមក ។ ចំណែកឈ្មោះ ល យគ វិញគាត់គ្មានដីកម្មសិទ្ធិនៅកន្លែងនោះទេ គាត់មានលិខិតស្នើសុំលក់ទឹកកកដែលមានចំណាររបស់ខេត្តអនុញ្ញាតអោយលក់ទឹកកកតែប៉ុណ្ណោះ ហើយក៏មកយកដីចំណីថ្នល់ត្រង់មុខផ្ទះ ល ម៩ លក់ទឹកកកតែម្តងទៅ ដោយពោលពាក្យថា ដីនេះឱ្យក៏លក់មិនឱ្យក៏លក់ដែរ ព្រោះអាងលើខេត្តអនុញ្ញាតឱ្យតែការពិតខេត្តអនុញ្ញាតឱ្យតែលក់ទឹកកកទេ ត្រង់ដីសំរាប់អោយលក់នោះខេត្តមិនបានចារអនុញ្ញាតអោយឡើយ ។ ក្រោយមកដីទំនាស់នេះខ្លួនធ្លាប់ឮដើមចោទថា ឈ្មោះ ល យគ បានធ្វើតូបពង្រីកជាងមុនជាច្រើនដង តែដើមចោទបានប្តឹងឃាត់រាល់ទង្វើទាំងនេះជាច្រើនដងដែរ រហូតចុងក្រោយឈ្មោះ ល យគ ធ្វើតូបចូលដីដើមចោទ ទើបគេប្តឹងមកតុលាការខេត្តទៀត ។

-សាក្សីដើមចោទឈ្មោះ ស ៩ បានឆ្លើយបញ្ជាក់ថា ដីទំនាស់នេះកាលពីដើមឡើយ គឺជាដីលំនៅដ្ឋានរបស់ឈ្មោះ ស ហ ប្តីឈ្មោះ ម ហ កាន់កាប់តាំងពីឆ្នាំ ១៩៧៩ មកដល់ឆ្នាំ ១៩៨៦ គាត់បានលក់ឱ្យទៅឈ្មោះ ច សហ ប្រពន្ធរបស់លោក ល ម៩ ជាដើមចោទពួកគេក៏កាន់កាប់រហូតមក ។ ចំណែកឈ្មោះ ល យគ វិញគាត់គ្មានដីកម្មសិទ្ធិនៅកន្លែងនោះទេ ខ្លួនឃើញគាត់លក់ទឹកកកមានតូបតូចមួយនៅមុខផ្ទះ ល ម៩ ត្រង់ដីចំណីថ្នល់លុះក្រោយមកគាត់ធ្វើតូបធំឈ្មោះ ល ម៩ ប្តឹងមិនឱ្យធ្វើ ក៏មានទំនាស់នឹងគ្នាជាច្រើនលើកអំពីការសាងសង់តូបនេះ

ដល់ឆ្នាំ ២០០៤ ឈ្មោះ **លយគ** ប្រុងរុះរើតូបចាស់ ហើយធ្វើឡើងថ្មីទៀត ក៏ត្រូវឈ្មោះ **លមថ** ប្ដឹងមកតុលាការខេត្តតែម្ដង ។

-បានឃើញប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ហាស់៣:៣៦៨ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៥ របស់នាយកដ្ឋានសុរិយោដី ។

-បានឃើញកំណត់ហេតុប្រគល់ និង ទទួលប្រាក់ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥ របស់តុលាការខេត្តកំពង់ធំ ។

**តំណាងអយ្យការសន្និដ្ឋានថា :**

ចំពោះរឿងក្ដីនេះអយ្យការស្នើសុំតុលាការសំរេចតាមច្បាប់ ។

-ក្រោយពីបានស្ដាប់ដើមចោទឆ្លើយអោយការណ៍ និង ប្ដឹងសុំ

-ក្រោយពីបានស្ដាប់ចម្លើយដោះសាររបស់ចុងចម្លើយ

-ក្រោយពីបានស្ដាប់ចម្លើយសាក្សីរបស់ដើមចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការខេត្តកំពង់ធំ**

-យល់ឃើញថា : ពាក្យបណ្ដឹងចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៤ របស់ដើមចោទឈ្មោះ **លមថ** មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-យល់ឃើញថា : ដើមចោទឈ្មោះ **លមថ** បានប្ដឹងសុំឱ្យចុងចម្លើយឈ្មោះ **លយគ** រុះរើតូបចេញពីមុខប្លង់ដីលំនៅដ្ឋានរបស់ខ្លួនដោយសំអាងហេតុថា ខ្លួនបានកាន់កាប់គ្រប់គ្រងដីលំនៅដ្ឋាននេះតាំងពីឆ្នាំ ១៩៨៦ មកមានទំហំ 0១អារ ៦៩សង់ទីអារ ដីនេះប្រពន្ធខ្លួនបានទិញពីបងស្រីបង្កើត ដែលគាត់កាន់កាប់តាំងពីឆ្នាំ ១៩៧៩ មក ឯឈ្មោះ **លយគ** គាត់មកធ្វើតូបលក់ទឹកកកនៅពីមុខប្លង់ខ្លួន ហើយមានបំណងធ្វើជាផ្ទះថ្មធំពីរជាន់ ។

-យល់ឃើញថា : គូភាគីបានព្រមព្រៀងឯកភាពគ្នា ដោយដើមចោទឈ្មោះ **លមថ** សុខចិត្តប្រគល់ប្រាក់ចំនួន ១.000ដុល្លាអាមេរិក ឱ្យទៅចុងចម្លើយឈ្មោះ **លយគ** ហើយចុងចម្លើយឈ្មោះ **លយគ** សុខចិត្តរុះរើតូបរបស់ខ្លួនចេញពីមុខប្លង់ដីរបស់ដើមចោទអោយហើយ ស្រេចត្រឹមថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៥ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-យល់ឃើញថា ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ហាស់៣:៣៦៨ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៥ របស់ដើមចោទឈ្មោះ **លមថ** មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

**ហេតុដូច្នេះតុលាការខេត្តកំពង់ធំ**

**វិនិច្ឆ័យសេចក្ដី**

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៤ របស់ដើមចោទឈ្មោះ **លមថ** ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទទួលស្គាល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ហាស់៣៉៣៦៨ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៥ របស់ដើមចោទឈ្មោះ ល មឪ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣-បង្គាប់អោយចុងចម្លើយឈ្មោះ ល យគ រុះរើតូបរបស់ខ្លួនចេញពីដីចំណីផ្លូវជាប់ពីមុខដីកម្មសិទ្ធិកររបស់ដើមចោទ តាមការព្រមព្រៀងឯកភាពរបស់គូភាគី ចាប់ពីសាលក្រមនេះមានអានុភាពអនុវត្តតទៅ ។ តូបរបស់ចុងចម្លើយ ដែលនៅពីមុខប្លង់ដីរបស់ដើមចោទ ចុងចម្លើយបានរុះរើរួចហើយ ។

៤-បង្គាប់អោយដើមចោទឈ្មោះ ល មឪ ប្រគល់ប្រាក់ ១.០០០ដុល្លាអាមេរិក ឱ្យទៅចុងចម្លើយឈ្មោះ ល យគ តាមការព្រមព្រៀងឯកភាពរបស់គូភាគី ។ ប្រាក់នេះចុងចម្លើយឈ្មោះ ល យគ បានទទួលគ្រប់ចំនួនតាមកំណត់ហេតុប្រគល់ និង ទទួលប្រាក់ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ របស់តុលាការខេត្តកំពង់ធំរួចហើយ ។

៥-បង្គាប់អោយចុងចម្លើយឈ្មោះ ល យគ បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី ពន្ធហ្វឹង ១.៨០០រ០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ០០ រង្វាន់ប្រគល់ដីកាកោះ ៥.០០០រ០០ សរុប ៧.០០០រ០០ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ០០ ដែលដើមចោទបានបង់រួចហើយ ផុតកំណត់ឧទ្ធរណ៍ឱ្យចុងចម្លើយសងទៅដើមចោទវិញ ។

៦-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញ
ចៅក្រមជំនុំជំរះ
[redacted]